៥៦-ទណ្ឌិតឈ្មោះ **ផល សំអាត** ភេទប្រុស អាយុ ១៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៤-២០០៧ ពីបទ ប្លន់ (វាយយកទូរស័ព្ទ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦៩ "ក្រ២" ចុះថ្ងៃទី ០២-៦-២០០៩ របស់សាលារាជធានីភ្នំពេញ ។

៥៧-ទណ្ឌិតឈ្មោះ **ហួម សុខហៀម** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-១[illegible]-២០០៨ ពីបទ សញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៤ "ង" ចុះថ្ងៃទី ១២-៨-២០១០ របស់សាលាឧទ្ធរណ៍

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

៥៨-ទណ្ឌិតឈ្មោះ **គង់ សុខហេង** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៣-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៤ "ស" ចុះថ្ងៃទី ១៤-៩-២០០៩ របស់សាលាឧទ្ធរណ៍ ។

៥៩-ទណ្ឌិតឈ្មោះ **មីន សែម** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៣-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ "ឆ" ចុះថ្ងៃទី ១៩-៩-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦០-ទណ្ឌិតឈ្មោះ **ជា យឿង** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-០២-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ "ច" ចុះថ្ងៃទី ២៦-៩-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦១-ទណ្ឌិតឈ្មោះ **ចឺន ឌីន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-០២-២០០៦ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ "ឃ" ចុះថ្ងៃទី ១៤-៨-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦២-ទណ្ឌិតឈ្មោះ **ហេង ម៉េងទ្រី** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៩-២០០៤ ពីបទ ជួញដូរចែកចាយគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤០ "ក" ចុះថ្ងៃទី ២៨-៤-២០០៥ របស់សាលាដំបូងខេត្តកំពង់ចាម ។

៦៣-ទណ្ឌិតឈ្មោះ **ម៉ាយ យ៉ាំងគៀង** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៥-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ "ក្រ.ខ" ចុះថ្ងៃទី ១៨-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦៤-ទណ្ឌិតឈ្មោះ **ខៀង យ៉ាំងជាង** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៥-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ "ក្រ.ខ" ចុះថ្ងៃទី ១៨-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦៥-ទណ្ឌិតឈ្មោះ **កេត ឡុងម៉ាលីស** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-២-២០០៧ ពីបទ ប្លន់ (ម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៣៣ ចុះថ្ងៃទី ១៣-១០-២០១០ របស់តុលាការកំពូល ។

៦៦-ទណ្ឌិតឈ្មោះ **អាឡិចសាន់ដឺ ត្រូហ្វីម៉ូវ** ហៅ សាសា (ALEXANDER TROFIMOV) ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១២-២០០៧ ពីបទ ទិញពេស្យាចារកុមារ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមដីកាលេខ ៥១ "ស" ចុះថ្ងៃទី ២៦-៨-២០១០ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ៥** : ត្រូវលើកលែងទោសឲ្យទណ្ឌិតចំនួន ២៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបាន ល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **ហេង ធីន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៥-២០០៣ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ តាមសាលក្រមលេខ ២០ ចុះថ្ងៃទី ៣០-៩-២០០៣ របស់សាលា ដំបូងខេត្តព្រះវិហារ ។

២-ទណ្ឌិតឈ្មោះ **យ៉ ធីហឿន** ភេទស្រី អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១១-២០០៨ ពីបទ សញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៣ ឆ្នាំ តាមសាលក្រមលេខ ២០ "ង" ចុះថ្ងៃទី ០៥-៥-២០០៩ របស់សាលា ដំបូងខេត្តព្រះសីហនុ ។

៣-ទណ្ឌិតឈ្មោះ **ទេស រ៉ូប៊ី** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៦-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមសាលក្រមលេខ ២៣ "ខ" ចុះថ្ងៃទី ២៦-៤-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៤-ទណ្ឌិតឈ្មោះ **មូ រ៉ាទី** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៦-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមសាលក្រមលេខ ២៣ "ខ" ចុះថ្ងៃទី ២៦-៤-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៥-ទណ្ឌិតឈ្មោះ **យុទ្ធ តណ្ហា** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៧-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិពលរដ្ឋ (ម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមសាលក្រមលេខ ០៤ ចុះថ្ងៃទី ២៥-១១-២០០៥ របស់សាលាដំបូងខេត្តកំពត ។

៦-ទណ្ឌិតឈ្មោះ **ហេង តាន់គីមហ៊ាង** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅ ថ្ងៃទី ២៧-១០-២០០៦ ពីបទ ប្លន់ និងប្រើប្រាស់អាវុធគ្រឿងផ្ទុះដោយគ្មានការអនុញ្ញាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមសាលក្រម លេខ ១៦ "គ" ចុះថ្ងៃទី ២១-០២-២០០៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៧-ទណ្ឌិតឈ្មោះ **សុខ លី** ភេទស្រី អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៥-២០០៨ ពីបទ សញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៥ "ង" ចុះថ្ងៃទី ០១-១២-២០០៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៨-ទណ្ឌិតឈ្មោះ **ពៅ ចន្ធូរ** ភេទស្រី អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៣-២០០៥ ពីបទ អំពើសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤២ "ក" ចុះថ្ងៃទី ២៥-៨-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៩-ទណ្ឌិតឈ្មោះ **ជា ទ្រី** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៧-២០០៨ ពីបទ ប្រើប្រាស់គ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១២ "ឃ" ចុះថ្ងៃទី ០៣-៣-២០០៩ និងសាលក្រមលេខ ៩៥ "ឆ" ចុះថ្ងៃទី ១៥-១១-២០០៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១០-ទណ្ឌិតឈ្មោះ **ហឿន សុខ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៤-២០០៦ ពីបទ ប្លន់ (វាយកាប់យកម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ "ឆ" ចុះថ្ងៃទី ២៨-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១១-ទណ្ឌិតឈ្មោះ **អ៊ិន ណារិន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៦-២០០៦ ពីបទ ប្លន់ (លួចគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០៤ "ដ" ចុះថ្ងៃទី ០៦-១២-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១២-ទណ្ឌិតឈ្មោះ **សៅ ឧត្តា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-២០០៦ ពីបទ ប្លន់ (កាត់ខ្សែកាប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ឈ" ចុះថ្ងៃទី ០៨-០២-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៣-ទណ្ឌិតឈ្មោះ **កែវ តុលឈីវ** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-២០០៦ ពីបទ ប្លន់ (កាត់ខ្សែកាប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ឈ" ចុះថ្ងៃទី ០៨-០២-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៤-ទណ្ឌិតឈ្មោះ **ស៊ុន ទ៉ាន់ស៊ី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៨-២០០៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ញ" ចុះថ្ងៃទី ២៤-១២-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

ROYAUME DU CAMBODGE MINISTRE DU PALAIS
18/2011

១៥-ទណ្ឌិតឈ្មោះ **ខេន ចាន់** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៥-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦០ "ក" ចុះថ្ងៃទី ២៣-១១-២០០៥ របស់សាលាដំបូងខេត្តកំពង់ចាម ។

១៦-ទណ្ឌិតឈ្មោះ **យន់ សាម៉ន** ភេទស្រី អាយុ ៦៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-២០០៦ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៥ "ឆ" ចុះថ្ងៃទី ១៧-៨-២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ។

១៧-ទណ្ឌិតឈ្មោះ **ស៊ីម ម៉ៃ** ភេទស្រី អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៨-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ "ឆ" ចុះថ្ងៃទី ១៨-០១-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

១៨-ទណ្ឌិតឈ្មោះ **តុល ស្រុខ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៧-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "ខ" ចុះថ្ងៃទី ១៥-៦-២០០៧ របស់សាលាដំបូងខេត្តកំពង់ចាម ។

១៩-ទណ្ឌិតឈ្មោះ **សេខ ទន់យូ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៣-២០០៥ ពីបទ ក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤២ "ឆ" ចុះថ្ងៃទី ០៧-៥-២០០៩ របស់សាលាឧទ្ធរណ៍ ។

២០-ទណ្ឌិតឈ្មោះ **យិន ចិន្តា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១០-២០០៤ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "គ" ចុះថ្ងៃទី ០២-៦-២០០៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២១-ទណ្ឌិតឈ្មោះ **ចុន តា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៥-២០០៧ពីបទ ប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៨ "ស" ចុះថ្ងៃទី ០២-១០-២០០៩ របស់សាលាឧទ្ធរណ៍ ។

២២-ទណ្ឌិតឈ្មោះ **សៀង បញ្ញា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-៨-២០០៦ ពីបទ ប្លន់ (វាយយកទ្រព្យសម្បត្តិអ្នកដទៃ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៩ "ច" ចុះថ្ងៃទី ១៤-១២-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

២៣-ទណ្ឌិតឈ្មោះ **នួន ចាន់ធឿន** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៨-២០០៧ ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៨ "ក្រ៥" ចុះថ្ងៃទី ១២-៦-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

២៤-ទណ្ឌិតឈ្មោះ **លីម ហេង** ហៅ ឡុក ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-២០០៩ ពីបទ បៀតបៀនកេរ្តិ៍ខ្មាស់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ណ" ចុះថ្ងៃទី ០៥-៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

២៥-ទណ្ឌិតឈ្មោះ **ហ័ង ហ្វាងហូ** (HUANG FANG HOU) ភេទប្រុស អាយុ ៩៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៥-២០០៦ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៧ "ច" ចុះថ្ងៃទី ២៦-០១-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៦-ទណ្ឌិតឈ្មោះ **ចឡូ សុធា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-១២-២០០៣ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦១ "គ" ចុះថ្ងៃទី ២៩-៧-២០០៩ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ៦** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១១០៥.៣៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៣៨៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនភេន

# ព្រះរាជក្រឹត្យ

នស/រកត/១៩០១១/៣៩៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ឌឿន សុវណ្ណ** អត្តលេខ ០២១៦៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧ល.១១០៥.៤០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៣៧៨ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៣៩៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យលសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ព្រះរាជក្រឹត្យ

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **សុខ សាផល** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **សូស ចណ្ណា** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍ និងទទួលមរណៈភាព

២- ឯកឧត្តម **អ៊ា រតនសាន** ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសឯកឧត្តម **ហូ សារ៉ាន់** ដែលត្រូវបានទទួលភារកិច្ចថ្មី

៣- ឯកឧត្តម **សឺន សុថា** ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសឯកឧត្តម **ទេស អែតដា** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៥.៤០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៣៨៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៣៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឆាល់ ចន្ទតារា** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនទទួលប្រាក់បៀវត្ស ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៥.៤០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៣៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៣៩៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហារាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកស្រីវរសេនីយ៍ឯក **ថនសុវណ្ណា ច័ន្ទខេម៉ា** អត្តលេខ ៥៤៥៦៣ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១១០៥.៤០៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១3 ខែ ឧសភា ឆ្នាំ ២០១១

លេខ ៣៨៥ ច.ល
ផ្ញើជូនចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១១
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

យ៉ុន ជីនរ៉េន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឥស្សរជន ០២រូប នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម មានគុណបំណាច់ខ្ពស់
ក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :
ឯកឧត្តម ទី ចំរុងផល
ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :
ឯកឧត្តម សាន វឌ្ឍនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៥.៤១០

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

លេខ: ៤៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនរតន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងទីប្រឹក្សានៃរដ្ឋលេខាធិការដ្ឋានអាកាចរស៊ីវិលៈ

១-ឯកឧត្តម **ឆិត្យ ចន្ថា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **ស៊ិន្ធ សាកល** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៥.៤១១

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១១

លេខៈ ៤១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **យឹម ស៊ីមុន្នី** អត្តលេខ ០៣៦២៧ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១១០៥. ៤១២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

លេខ: ៤១១ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនភេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការស៊ីវិលនៅខេត្តព្រៃវែងចំនួន ៥១ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបំរើ ជាតិមាតុភូមិ និង ស្មារតីទទួលខុសត្រូវខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

**នូវ**

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

| | | | |
|---|---|---|---|
| ១-លោក | **កែវ សេន** | ៤-លោក | **ថង គៀន** |
| ២-លោក | **ម៉ុក ឆារី** | ៥-លោក | **អ៊ុំ ប៊ុនឡេង** |
| ៣-លោកស្រី | **ឆេព្វ សំអួន** | | |

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

| | | | |
|---|---|---|---|
| ១-លោក | **ម៉ារ សារិន** | ៣-លោក | **ឌួន សុគន្ធា** |
| ២-លោក | **សោម រតនៈ** | ៤-លោក | **យស់ ធុល** |

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

| | | | |
|---|---|---|---|
| ១-លោក | **ម៉ៅ អ៊ាង** | ៩-លោក | **គេ អ៊ុម** |
| ២-លោក | **ប្រាក់ សុវណ្ណ** | ១០-លោក | **ម៉ៅ គីមឡុង** |
| ៣-លោក | **សយ សុត** | ១១-លោក | **ចាន់ វ៉ាន់** |
| ៤-លោក | **ជា ស្រួយ** | ១២-លោក | **សៅ ប្រសិដ្ឋ** |
| ៥-លោក | **ចាន់ ដេត** | ១៣-លោក | **ហ៊ី ធូក** |
| ៦-លោក | **ស៊ិន សារៈ** | ១៤-លោក | **ប៉ោ ពីឡុត** |
| ៧-លោក | **ឡុង ថាត** | ១៥-លោក | **នៅ សុគន្ធ** |
| ៨-លោក | **ពុធ សារុន** | ១៦-លោកស្រី | **ឆាន រស់សាលី** |

| | | | |
|---|---|---|---|
| ១៧-លោកស្រី | ភោគ ណារិន | ២០-លោក | យឹម យុគន់ |
| ១៨-លោក | ឡុង ចន្ថា | ២១-លោក | ម៉ី ឧត្តរា |
| ១៩-លោក | ហ៊ុល ចំរើន | ២២-លោក | ឡាច តិរ៉ាត់ |

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **អស្សឫទ្ធិ** :

| | | | |
|---|---|---|---|
| ១-លោក | ប្រាក់ សេង | ១១-លោកស្រី | គិន សាវ៉ាត |
| ២-លោក | ប្រាក់ ម៉ុនណា | ១២-លោក | ខឡុ សោភ័ណ |
| ៣-លោក | និត ចិន្តា | ១៣-លោកស្រី | ផាត់ សុផានៀន |
| ៤-លោក | ប្រាជ្ញ សារ៉េន | ១៤-លោក | ឃុន សារឿន |
| ៥-លោក | ឈុំ ឆោម | ១៥-លោក | ស៊ិន សារឿន |
| ៦-លោក | យ៉យ សុផុន | ១៦-លោកស្រី | ឯក សុនណាវី |
| ៧-លោក | ស្នោញ សុគី | ១៧-លោក | ហ៊ុល ចាន់ថន |
| ៨-លោកស្រី | ឡេង រ៉ា | ១៨-លោកស្រី | ច័ន្ទ ម៉ាឡង់ធីណា |
| ៩-លោកស្រី | ម៉ម សាវឿន | ១៩-លោកស្រី | រស់ សុផល |
| ១០-លោកស្រី | សៅ ចន្ថា | ២០-លោកស្រី | ឯម មុំ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៥.៤១៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៤០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤១០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក សប្បុរសជន អ្នកស្ម័គ្រចិត្ត យុវជន និងអនុសាខា នៃសាខាកាកបាទក្រហមកម្ពុជា
ខេត្តបាត់ដំបង កំពត កំពង់ចាម និងកោះកុង បម្រើសកម្មភាពមនុស្សធម៌
របស់កាកបាទក្រហមកម្ពុជា ចំនួន ១០រូប

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១- ឯកឧត្តម ប្រាជ្ញ ចន្ទ
២- ឯកឧត្តម អ៊ុក វចន្ស
៣- ឯកឧត្តមឧកញ៉ាបណ្ឌិត ប៊ុត គីមស៊ាន
៤- ឯកឧត្តមវេជ្ជបណ្ឌិត ញឹក ប៊ុនឈុប
៥- ឯកឧត្តម ហ៊ុន ណេង
៦- ឯកឧត្តមឧកញ៉ា ម៉ក់ គីមហុង
៧- ឯកឧត្តម ឡាន់ ឆន
៨- ឯកឧត្តមឧកញ៉ា ខូច ផល្លាបុត្រ
៩- លោកជំទាវ ឈួង ចារីក
១០- ឯកឧត្តម អ៊ុន ឆាលី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១១០៥. ៤១៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

លេខ: ៤៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក សប្បុរសជន អ្នកស្ម័គ្រចិត្ត យុវជន និងអនុសាខា នៃសាខាកាកបាទក្រហមកម្ពុជា
ខេត្តបាត់ដំបង កំពត កំពង់ចាម និងកោះកុង បម្រើសកម្មភាពមនុស្សធម៌
របស់កាកបាទក្រហមកម្ពុជា ចំនួន ០៩ រូប

នូវ

១ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

- ១- លោក ម៉ុង យ៉េន
- ២- ឧត្តមសេនីយ៍ទោ ជឿន សុវណ្ណថា
- ៣- លោកជំទាវ អេង គឹមនាង
- ៤- លោក សាំង សាគុណ

២ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

- ១- លោក ភង ប៊ិន
- ២- លោក កែវ ចន្ទណារ៉េត
- ៣- លោកស្រី យូ សុគន្ធ
- ៤- លោក វង់ វ៉ាន់
- ៥- លោក លី សារ៉េត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៥៧៣ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រប.១១០៥.៤១៦

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១១

ស៊ុន ចិនតេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤១២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំង ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន០៥រូប មានឋានៈស្មើ អគ្គនាយក ដូចមានរាយនាមខាងក្រោម:

១- ឯកឧត្តម **លន់ រណេត**
២- ឯកឧត្តម **ថន អ៊ឹម**
៣- ឯកឧត្តម **សុខ សាររេត**
៤- ឯកឧត្តម **សារ៉ាយ នុន**
៥- ឯកឧត្តម **ហ៊ូ សេងលន់** ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៥.៤១៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១១

លេខៈ ៤១០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] **ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩០០ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ដែនជម្រកសត្វព្រៃភ្នំណាមល្យើរ ភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង ប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៥០០(ប្រាំរយ) ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀវ ភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៩៣ សជណ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៦ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៨២៥ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៨.៨២៥(ប្រាំបីពាន់ប្រាំបីរយម្ភៃប្រាំ)ហិកតាក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគីរី ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ២៤១ សជណ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩៥០ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃលំផាត់ ក្នុងស្រុកលំផាត់ ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១.៩៥០(មួយពាន់ប្រាំបួនរយហាសិប) ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ២៣៤ សជណ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៤ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៧១៨ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស" បូកគោ" ភូមិសាស្ត្រស្រុកដងទង់ និង ស្រុកឈូក ខេត្តកំពត**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៦.៧១៨(ប្រាំមួយពាន់ប្រាំពីររយដប់ប្រាំបី) ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ភូមិសាស្ត្រស្រុកជុំគិរី និងស្រុកឈូក ខេត្តកំពត ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១០៩ សជណ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៩ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០០០ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង និងស្រុកអណ្តូងមាស ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៩.អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩.000( ប្រាំបួនពាន់) ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង និងស្រុកអណ្ដូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៦០ សជណ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៩៩៨ ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង ខេត្តរតនគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៨.អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៨.៩៩៨(ប្រាំបីពាន់ប្រាំបួនរយកៅសិបប្រាំបី) ហិកតា ក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៥៩ សជណ ចុះថ្ងៃ ទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥៥ .អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គលេខាធិការគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ កីឡាករ កីឡាការិនី គ្រូបង្វឹក និងគ្រូជំនួយចំនួន១៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមប្រកួតកីឡាអាស៊ីប៉ារ៉ាហ្គេមលើកទី១ នៅទីក្រុងហ្គង់ចូវ ប្រទេសចិន កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

| | | | |
|---|---|---|---|
| ១-លោក | **អ៊ិន** | **សុខអេង** | គ្រូបង្វឹក |
| ២-លោក | **ជឹម** | **ផាន** | កីឡាករ |
| ៣-លោក | **គីម** | **វណ្ណា** | កីឡាករ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

១-លោកជំទាវនៅ **លក្ខិណា** ភរិយាឯកឧត្តម **យី វាសនា** និងជាជំនួយការអគ្គលេខាធិការគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា

| | | | |
|---|---|---|---|
| ២-លោក | **ម៉ៅ** | **សុជា** | ប្រធានប្រតិភូកីឡាករ |
| ៣-លោក | **ហែម** | **លំផាត់** | គ្រូបង្វឹក |
| ៤-លោក | **ផៃ** | **សុខ** | គ្រូជំនួយ |
| ៥-លោក | **យែម** | **បៃ** | គ្រូជំនួយ |
| ៦-លោក | **មុខ** | **ហុង** | កីឡាករ |
| ៧-លោក | **គន** | **ភាន** | កីឡាករ |

| | | | |
|---|---|---|---|
| ៨-កញ្ញា | ធិន | សេងហុន | កីឡាការិនី |
| ៩-លោក | ឈុប | រដ្ឋា | កីឡាករ |
| ១០-លោក | ហ៊ុន | ប៊ុនធិត្យ | កីឡាករ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ជូន ក្រុមគ្រូពេទ្យ របស់មន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម និងមន្ទីរពេទ្យភ្នែក ទីក្រុងហូជីមិញ ចំនួន ១៥ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ និងបានជួយវះកាត់ព្យាបាលភ្នែកឡើងបាយ ជូនកងទ័ព និងប្រជាជនក្រីក្រកម្ពុជា ចំនួន ០៩ លើក ដូចមានរាយនាមខាងក្រោម ÷

**ក.មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

១- ឧត្តមសេនីយ៍ត្រី **ង្វៀន ហ្វុកគួក** ( General Ts NGUYEN PHUC QUOC ) នាយកមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

២- ឧត្តមសេនីយ៍ត្រី **ង្វៀន វ៉ាន់ប៊ិញ** ( General Ts NGUYEN VAN BINH ) ប្រធាននយោបាយមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

៣- លោកស្រីវេជ្ជបណ្ឌិត **ចិនធិ ភឿងធូ** ( Mrs Ts TRAN THI PHUONG THU ) នាយកមន្ទីរពេទ្យភ្នែកក្រុងហូជីមិញ

**ខ.មេដាយសហមេត្រី ថ្នាក់ សេនា**

១- ឧត្តមសេនីយ៍ត្រី **ហ័ង ថាញ់ប៊ិញ** ( General Ts HOANG THANH BINH ) នាយករងមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

២- វរសេនីយ៍ឯក **ង្វៀន បាសឺន** ( Colonel Ts NGUYEN BA SON ) នាយករងមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

៣- វរសេនីយ៍ឯក **ង្វៀន កុងទ្រីង** ( Colonel Bs NGUYEN CONG TRINH ) ប្រធានការិយាល័យផែនការបច្ចេកទេស មន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

៤- វរសេនីយ៍ឯក **ង្វៀន ថេវឿង** ( Colonel Bs NGUYEN THE VUONG ) នាយរងការិយាល័យផែនការបច្ចេកទេស មន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

៥- វរសេនីយ៍ឯកបំរ៉ុង **ហ្វី វិញបាវ** ( Colonel Bs PHI VINH BAO ) ប្រធានអាគារភ្នែក មន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

៦- វរសេនីយ៍ឯកបំរ៉ុង **ដូ ទុងឡឹម** ( Colonel Bs DO TUNG LAM ) អនុប្រធានអាគារភ្នែក មន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

៧- លោកបណ្ឌិត **ង្វៀន ថាញ់ណាម** ( Mr Ts NGUYEN THANH NAM ) អនុប្រធានអាគារវះកាត់ភ្នែក និងកែសម្ផស្ស មន្ទីរពេទ្យភ្នែកក្រុងហូជីមិញ

**គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ**

១- វរសេនីយ៍ឯកបំរ៉ុង **ចិន វ៉ាន់ថាញ់** ( Colonel Bs TRAN VAN THANH ) ជំនួយការការិយាល័យផែនការបច្ចេកទេ សមន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

២- វរសេនីយ៍ឯកបំរ៉ុង **ង្វៀន ទៀនធិញ** ( Colonel Bs NGUYEN TIEN TINH ) ជំនួយការការិយាល័យផែនការបច្ចេកទេ សមន្ទីរពេទ្យ១៧៥ កងទ័ពប្រជាជនវៀតណាម

៣- លោកគ្រូពេទ្យ **ឡេ អាញ់ហ៊ុយ** ( Mr LE ANH HUY ) គ្រូពេទ្យផ្នែកសណ្តំមន្ទីរពេទ្យភ្នែក ទីក្រុងហូជីមិញ

៤- លោកស្រី **ដូ ចិនង៉ុកថាច់** ( Mrs DO TRAN NGOC THACH ) គ្រូពេទ្យផ្នែកសណ្តំ មន្ទីរពេទ្យភ្នែក ទីក្រុងហូជីមិញ

៥- លោកស្រី **ដាំង ចិនវូហាន** ( Mrs DANG TRAN VU HAN ) គ្រូពេទ្យផ្នែកវះកាត់ មន្ទីរពេទ្យភ្នែក ទីក្រុងហូជីមិញ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ** ជូន អនុព័ន្ធយោធា ចំនួន ០៣ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ត្រូវចប់អាណត្តិ ដូចមានរាយនាមខាងក្រោម ÷

១- វរសេនីយ៍ឯក **អែនឌ្រីយ៍ នីដហ្សៀ** ( Colonel Andrey Nidziy ) នាយរងការិយាល័យអនុព័ន្ធយោធាសហព័ន្ធរុស្ស៊ី

២- វរសេនីយ៍ឯក **វីឆៀន ថមម៉ាថន** ( Colonel Vichian Thammathorn ) នាយរងការិយាល័យអនុព័ន្ធយោធាជើងអាកាស ព្រះរាជាណាចក្រថៃ

៣- វរសេនីយ៍ទោ **ដាមាន ដឺបេសាំបេស្ស** ( Lieutenant Colonel Damien De Besombes ) ប្រធានបេសកកម្មសហប្រតិបត្តិការយោធា និងការពារបារាំង

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់មេដាយសុវត្ថារាតាមលំដាប់ថ្នាក់ជូនលោកស្រី អស់លោក ជានាយនគរបាលជាតិ មន្ត្រីរាជការ និងសប្បុរសជន បានចូលរួមចំណែកក្នុងការអភិវឌ្ឍលើគ្រប់វិស័យតាមមូលដ្ឋាននានា ក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

**ក. មេដាយសុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- លោក **សាងម សេដ្ឋា** | អភិបាលរងស្រុកថ្មគោល ខេត្តបាត់ដំបង |
| ២- លោកស្រី **រស់ ស៊ីថា** | អភិបាលរងស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៣- លោក **ពៅ ភាររម្យ** | អភិបាលរងស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៤- លោកវរសេនីយ៍ទោ **ហ៊ីង ចណ្ណី** | ការិ.កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| ៥- លោកវរសេនីយ៍ទោ **ស្រ៊ុន គន្ធា** | នាយទាហានការពារផ្ទាល់បញ្ជាការដ្ឋានអង្គរក្ស |
| ៦- លោក **សេង ស្រេង** | នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៧- លោក **ឃួ ឌី** | ប្រធានការិយាល័យវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៨- លោក **ឌិត ជីន** | សប្បុរសជននៅខេត្តបាត់ដំបង |

**ខ. មេដាយសុវត្ថារា ថ្នាក់សេនា :**

| | |
|---|---|
| ១- លោក **អ៊ាង សារ៉ុម** | សមាជិកក្រុមប្រឹក្សាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ២- លោក **គោត ភិរុណ** | សមាជិកក្រុមប្រឹក្សាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៣- លោក **ផៃ ទុន្នី** | សមាជិកក្រុមប្រឹក្សាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៤- លោកអនុសេនីយ៍ទោ **ម៉ែន តារា** | មន្ត្រីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ |
| ៥- លោកអនុសេនីយ៍ត្រី **ឡោ ឆេងឆេង** | នាយកដ្ឋាននគរបាលអន្តរជាតិ ក្រសួងមហាផ្ទៃ |

**គ. មេដាយសុវត្ថារា ថ្នាក់អស្សឫទ្ធិ :**

| | |
|---|---|
| ១- លោក **សេខ ស៊ីមសុរិយា** | នាយករដ្ឋបាលសាលាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ២- លោក **កៅ ឧល្លូណា** | នាយករងរដ្ឋបាលសាលាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៣- លោក **ណាក់ ស៊ុណារុន** | ប្រធានការិយាល័យរដ្ឋបាលសាលាស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៤- លោក **លូ ឈុន** | ប្រធានការិយាល័យអន្តរវិស័យ ស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៥- កញ្ញា **ប៊ូ ស៊ីណាត** | ប្រធានការិយាល័យផែនការ និងគាំទ្រឃុំ ស្រុកថ្មគោល ខេត្តបាត់ដំបង |
| ៦- លោកអនុសេនីយ៍ត្រី **ហួរ ស្រ៊ុនលី** | មន្ត្រីនាយកដ្ឋានបច្ចេកទេសព្រំដែន ក្រសួងមហាផ្ទៃ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២០៩ / ១២១១ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **ម៉ម សំ** អត្តលេខ ០០២៥១២ ជា អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ទោ **សេង វ៉ាន់ធី** អត្តលេខ ០០០៥៩០ ជា អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧០ . អនក្រ. បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ . បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ខួន ស៊ីវត្ថា** ឲ្យបំពេញមុខងារជា **អគ្គាធិការរង** នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ៣៣១២ កន្លែង (បីពាន់បីរយដប់ពីរ) ដល់ក្រសួងមហាផ្ទៃ សម្រាប់តម្រូវការចាំបាច់នៃការងារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។

**មាត្រា ២** : ក្របខ័ណ្ឌបំពេញថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិ ចាប់ពីខែ តុលា ឆ្នាំ ២០១១ តទៅ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- វរសេនីយ៍ទោ | **ខួន** | **វុទ្ធី** | អត្តលេខ ០៣២៥៩៨ | នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស |
| ២- វរសេនីយ៍ទោ | **រ័ត្ន** | **ប៊ុនធឿន** | អត្តលេខ ០១១៦៧៣ | នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស |
| ៣- វរសេនីយ៍ទោ | **ម៉ុន** | **វណ្ណៈ** | អត្តលេខ ០២១១៩៦ | នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស |

៤- វរសេនីយ៍ទោ **សន ឃុន** អត្តលេខ ០២១០៦៥ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

៥- វរសេនីយ៍ទោ **ល័ក្ខ ឌុច** អត្តលេខ ០២១១០៤ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

៦- វរសេនីយ៍ទោ **មុំ ម៉ុនធឿន** អត្តលេខ ១១០៥៨២ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

៧- វរសេនីយ៍ទោ **សុខ គីមលី** អត្តលេខ ១៦២៣៧២ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

៨- វរសេនីយ៍ទោ **ឈុន ថ័រ** អត្តលេខ ០៥៨៩៨២ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

៩- វរសេនីយ៍ទោ **សួន ស៊ីនឿន** អត្តលេខ ១៦២៣០១ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១០- វរសេនីយ៍ទោ **គន់ អៃហៀង** អត្តលេខ ០១១៧៥៦ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១១- វរសេនីយ៍ទោ **ម៉ុន ឃាង** អត្តលេខ ០៣២៦៤៧ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១២- វរសេនីយ៍ទោ **នូច ចាន់ធី** អត្តលេខ ១១២៤២៩ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៣- វរសេនីយ៍ទោ **ជ្រឿន ម៉ុនយ៉េល** អត្តលេខ ១៦២១៣៩ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៤- វរសេនីយ៍ទោ **ស៊ឹម ចិន្តា** អត្តលេខ ០២១១៧៣ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៥- វរសេនីយ៍ទោ **ឡឹក សុភី** អត្តលេខ ០២១១៤៣ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៦- វរសេនីយ៍ទោ **សោម ដារ៉ា** អត្តលេខ ០៣២៥៥៨ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៧- វរសេនីយ៍ទោ **ស្លាត សារណាន** អត្តលេខ ០៤៦៦៦៥ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៨- វរសេនីយ៍ទោ **ញូង សម្បត្តិ** អត្តលេខ ០១១៧០៨ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

១៩- វរសេនីយ៍ទោ **ម៉ា សុខស៊ីណាង** អត្តលេខ ០១៦៨៣៧ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២០- វរសេនីយ៍ទោ **សែ សុភាព** អត្តលេខ ០១១៧៧៧ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២១- វរសេនីយ៍ទោ **ម៉ិន សុភាព** អត្តលេខ ០១១៧០៥ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២២- វរសេនីយ៍ទោ **ខណ្ឌ ស៊ីថាឧត្តម** អត្តលេខ ១០៦៦៧១ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២៣- វរសេនីយ៍ទោ **ឡេង សាម៉េត** អត្តលេខ ១៣៧៦៨២ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២៤- វរសេនីយ៍ទោ **អ៊ុយ សារុំ** អត្តលេខ ១៦២៣២៤ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២៥- វរសេនីយ៍ទោ **អេង ចិត្រា** អត្តលេខ ០៣២៦៧២ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២៦- វរសេនីយ៍ទោ **សរ សេរីវិចិត្រ** អត្តលេខ ០៥៥៥០១ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ· រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាម ដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **សុខ ចារុវណ្ណ** អត្តលេខ ០០១០៩០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ទោ **សុខ សុវណ្ណ** អត្តលេខ ០០០៨៣៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឧត្តមសេនីយ៍ទោ **យ៉ង់ សារិទ្ធ** អត្តលេខ ០០២៥៧០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឧត្តមសេនីយ៍ទោ **នៅ សាវ៉ន** អត្តលេខ ០០៣៧៧៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឧត្តមសេនីយ៍ទោ **អ៊ុក សុទ្ធសេន** អត្តលេខ ០០៣៩៩៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៦-ឧត្តមសេនីយ៍ទោ **ម៉ិច សុខី** អត្តលេខ ០០២៣៥០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៧-ឧត្តមសេនីយ៍ទោ **រឿង ឧទ្ធី** អត្តលេខ ០០២៣៩៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៨-ឧត្តមសេនីយ៍ទោ **នួន ណារិទ្ធ** អត្តលេខ ០០១១០១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

៩-ឧត្តមសេនីយ៍ទោ **ស៊ឹម សុទ្ធ** អត្តលេខ ០០២៣៨៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១០-ឧត្តមសេនីយ៍ទោ **ចាន់ រ៉ា** អត្តលេខ ០០០៣៤១ ជានាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

១១-ឧត្តមសេនីយ៍ត្រី **ម៉ិត សុភាព** អត្តលេខ ០០២២៤១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១២-ឧត្តមសេនីយ៍ត្រី **ថាន់ សុខេន** អត្តលេខ ០០២២៨៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-ឧត្តមសេនីយ៍ត្រី **អន សារិទ្ធ** អត្តលេខ ០០៣២៥០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៤-ឧត្តមសេនីយ៍ត្រី **ចាន់ លី** អត្តលេខ ០២១០២៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៥-ឧត្តមសេនីយ៍ត្រី **ម៉ិន ដារ៉ា** អត្តលេខ ០០៥២៧៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៦-ឧត្តមសេនីយ៍ត្រី **ហួត សាបាន** អត្តលេខ ០០៤០៦៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៧-ឧត្តមសេនីយ៍ត្រី **កែវ អាន** អត្តលេខ ០០៥១៦៦ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៨-ឧត្តមសេនីយ៍ត្រី **ចាន់ ម៉ុណ្ណា** អត្តលេខ ០០៤០០៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៩-ឧត្តមសេនីយ៍ត្រី **ឡេង ម៉ុនណា** អត្តលេខ ២៣២៤០២ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២០-ឧត្តមសេនីយ៍ត្រី **អ៊ុំ សំអាត** អត្តលេខ ០០២៤១៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២១-ឧត្តមសេនីយ៍ត្រី **អន ណារ្គី** អត្តលេខ ០១១៦២៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២២-ឧត្តមសេនីយ៍ត្រី **ជា តារា** អត្តលេខ ០១០០៨៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២៣-ឧត្តមសេនីយ៍ត្រី **អ៊ុន នុត** អត្តលេខ ០១១៦៤៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២៤-ឧត្តមសេនីយ៍ត្រី **ឃុត ស៊ុនហេង** អត្តលេខ ០០២១៩៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការ ០២រូប ជាអភិបាលស្រុក នៅខេត្តបាត់ដំបង និងខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :

១-លោក **សើ សារ៉េត** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ៨ ជាអភិបាលស្រុករតនមណ្ឌល ខេត្តបាត់ដំបង ជំនួសលោក **សំ សៀក** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

២-លោក **ប៊ិច សុខ** ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១០ ជាអភិបាលស្រុកព្រះស្តេច ខេត្តព្រៃវែង ជំនួសលោក **ជា ស្រួយ** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៥ អនក្រ.តត

# អនុក្រឹត្យ

ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរបញ្ចូលទៅក្នុងឋានន្តរសក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការចំនួន **០៤រូប** ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- | លោកស្រី **ខ្លូត វណ្ណារ៉ា** | ឋានន្តរសក្តិ នាយក្រមការ | ថ្នាក់លេខ ៥ |
| ២- | លោក **អ៊ុត សុផាន់** | ឋានន្តរសក្តិ នាយក្រមការ | ថ្នាក់លេខ ៥ |
| ៣- | លោក **គង់ សំអាត** | ឋានន្តរសក្តិ នាយក្រមការ | ថ្នាក់លេខ ៦ |
| ៤- | លោក **ហ៊ុន ហូ** | ឋានន្តរសក្តិ នាយក្រមការ | ថ្នាក់លេខ ៦ ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ ប.ប

## បទបញ្ជារបស់រាជរដ្ឋាភិបាល
## ស្តីពីការចាត់វិធានការលុបបំបាត់ភាពអនាធិបតេយ្យ
## នៃការដាក់សំរះ ឆ្នស់ ព្រួល និងសំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ
## និងបឹងបួរ នៅតាមបណ្តាខេត្តពាក់ព័ន្ធនឹងបឹងទន្លេសាប

នៅក្នុងពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលសង្កេតឃើញថា នៅក្នុងភូមិសាស្ត្រខេត្តទាំង ៨ ជុំវិញបឹងទន្លេសាប រួមមាន : ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តកណ្តាល នៅមានសកម្មភាពដាក់សំរះ ឆ្នស់ ព្រួល និងសាងសង់សំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ ដែលសកម្មភាពអវិជ្ជមានទាំងនេះ បានបង្កជាឧបសគ្គដល់ការធ្វើចរាចរនៃជលយានគ្រប់ប្រភេទ របបជលសាស្ត្រ ការបំលាស់ទីរបស់មច្ឆជាតិគ្រប់ប្រភេទ ព្រមទាំងជាកត្តាបង្កឱ្យមានការគោករាក់យ៉ាងឆាប់រហ័សដល់ទន្លេ ស្ទឹង ព្រែក បឹងបួរ ទាំងនោះផងដែរ ។

ដើម្បីឈានទៅលុបបំបាត់ទាំងស្រុងនូវសកម្មភាពអនាធិបតេយ្យទាំងនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវបទបញ្ជាដល់ក្រសួង-ស្ថាប័ន និងអាជ្ញាធរខេត្តពាក់ព័ន្ធនឹងរបបជលសាស្ត្រនៃបឹងទន្លេសាបទាំងអស់ ដើម្បីចុះអនុវត្តតាមការណែនាំ ដូចខាងក្រោម :

១- ជំហានទី ១ : អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តកណ្តាលត្រូវអញ្ជើញម្ចាស់សំរះ ឆ្នស់ ព្រួល និងសំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ គ្រប់ប្រភេទ មកធ្វើការណែនាំ និងតម្រូវឱ្យរុះរើសំណង់ទាំងនោះចេញដោយខ្លួនឯង ដោយរាជរដ្ឋាភិបាលទុករយៈពេល ២ សប្តាហ៍ជូន ។

២- ជំហានទី ២ : ផុតរយៈពេលឱសានវាទ ( ២ សប្តាហ៍ ) ខាងលើ បើម្ចាស់សំណង់ទាំងនោះមិនធ្វើការរុះរើទេនោះ ក្រសួងធនធានទឹក និងឧតុនិយមនឹងសហការជាមួយអាជ្ញាធរទន្លេសាប អាជ្ញាធរខេត្តពាក់ព័ន្ធ និងកម្លាំងអន្តរាគមន៍ពិសេសចុះបំផ្លាញចោលទាំងស្រុង និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ដូចមានចែងត្រង់ចំណុច ៣ មាត្រា ៣៦ ជំពូកទី ១០ នៃ ច្បាប់ស្តីពី " ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា " ។ ម្ចាស់សំណង់ត្រូវចេញសោហ៊ុយសម្រាប់ការងារប្រតិបត្តិការខាងលើនេះ ។

៣- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអាជ្ញាធរទន្លេសាប អភិបាលនៃគណៈអភិបាលខេត្តទាំង ៨ ខាងលើ ប្រធានក្រុមអន្តរាគមន៍ពិសេសត្រូវអនុវត្តឱ្យបានសម្រេចនូវបទបញ្ជារបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងចំណុច ១ និងចំណុច ២ នៃបទបញ្ជានេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ :...៤.១៣.១៥៥..កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៥៥០ /១១ គ.វ.ក ចុះថ្ងៃទី២៥.០៣.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វង់ គួរី (ខេមបូឌា) មេនូហ្វេកធើរីង លីមីធីត ចុះថ្ងៃទី១៦.០៣.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វង់ គួរី (ខេមបូឌា) មេនូហ្វេកធើរីង លីមីធីត តំណាង ដោយ លោក CHOI LIN HUNG សញ្ជាតិអង់គ្លេស អាយុ៥៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 706091612 ចុះថ្ងៃទី២១.០៦.២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ 11th Floor, The Primrose, No.38 Rose St., Yau Yat Chuen, Kowloon, Hong Kong. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣

-ផ្លាកឈ្មោះរោងចក្រ ៖ *"ហ្វដ គ្លរី (ខេមបូឌា) មេនូហ្វេកធឺរីង លីមីធីត (FORD GLORY (CAMBODIA) MANUFACTURING LIMITED.)"*

-ទីតាំងរោងចក្រ ៖ *" ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។ ១៦ (signature initial)

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២**: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣**: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤**: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥**: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**ចម្លងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៣០១ ឧរថ.កឧ - ប្រក .

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែឧសភាឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ១២៣៣ ឧរថ.កឧ.ប្រក ចុះថ្ងៃទី៧.១២.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៦០៤/០៩ គ.វ.ក ចុះថ្ងៃទី២៣.០៧.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឌុង សុង អ៊ិនធើណេសិនណល ចុះថ្ងៃទី២១.១២.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឌុង សុង អ៊ិនធើណេសិនណល តំណាង ដោយ លោក CHIEN, CHENG-HSUAN សញ្ជាតិ ចិន(តៃវ៉ាន់) អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 210130116 ចុះថ្ងៃទី២៥.០៩.២០០៣ មានអាសយដ្ឋានបច្ចុប្បន្នៈ TAIWAN CHINA ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| បោះពុម្ពសម្លៀកបំពាក់ | ១៣១៣ |

-ផ្លាកឈ្មោះរោងចក្រ ៖ *" ឌុង សុង អ៊ិនធើណេសិនណល ( DONG SONG INTERNATIONAL CO., LTD. ) "*

-ទីតាំងរោងចក្រ ៖ *" ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្ដីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្ដីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្ដីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

